ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០២១.៦៤៩ ធក.ន.ណ.......

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី

(Marginal Lending Facility — MLF)

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឱ្យបានជ្រាបថា ក្នុងគោលបំណងបន្តអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុ ស្របតាមវឌ្ឍនភាពនៃប្រព័ន្ធធនាគារបច្ចុប្បន្ន និងដើម្បីជំរុញទីផ្សារអន្តរធនាគារឱ្យកាន់តែមានភាពល្អប្រសើរឡើងថែមទៀត ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យដំណើរការឧបករណ៍នយោបាយរូបិយវត្ថុថ្មីមួយគឺ ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ជាប្រាក់រៀល ចាប់ពីថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១។

ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) នេះ មានរយៈពេលមួយយប់ (Overnight) និងអាចពន្យារពេលបាន តិចជាង ឬស្មើប្រាំថ្ងៃ ដោយមានមូលបត្រអាចជួញដូរបាន (NCD) ជាវត្ថុធានា ដើម្បីជួយបំពេញកង្វះសន្ទនីយភាពរយៈពេលខ្លី ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានតម្រូវការ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានបំណងស្នើសុំ MLF សូមអញ្ជើញមកទទួលព័ត៌មានលម្អិត នៅនាយកដ្ឋានប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សូមទំនាក់ទំនង
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣ ឬ (៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
សារអេឡិចត្រូនិក :mlf_info@nbc.org.kh